មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

លេខ:..01679/12.../ម.ស.ម.ក/

ខ្ញុំបាទឈ្មោះ អ៊ូ ទីរ:
ប្រធាន មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)

សូមគោរពជូន
ឯកឧត្តម ស ខេង
ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

<u>កម្មវត្ថុ:</u> ស្នើសុំជួយអន្តរាគមន៍ស៊ើបអង្កេតជាបន្ទាន់មួយ ចំពោះការអនុវត្តខុសតួនាទីរបស់មន្ត្រីនគរបាលម្នាក់។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ នៅភូមិព្រែកជីក ឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង មានមន្ត្រីនគរបាលម្នាក់មកពីប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំជីខលើ បានធ្វើការគម្រាមដកហូតយកម៉ាស៊ីនថតពីបុគ្គលិកម្នាក់ របស់ ម.ស.ម.ក ខណៈដែលរូបគាត់ និងក្រុមការងាររបស់ ម.ស.ម.ក កំពុងឃ្លាំមើលព្រឹត្តិការណ៍ពាក់ព័ន្ធនឹងករណីជម្លោះដីធ្លីមួយ។ ហេតុការណ៍នោះបានកើតឡើង ដោយមន្ត្រីនគរបាលរូបនោះបានធ្វើតាមការបង្គាប់បញ្ជារបស់ថៅកែក្រុមហ៊ុន ហេង ហ៊ុយ អេហ្គ្រីខលឈ័រគ្រូប។

វេលាម៉ោងប្រមាណជា ៩:៣០ នាទីព្រឹក ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ មន្ត្រីនគរបាលម្នាក់ឈ្មោះ ង៉ី សុខុន ក្នុងឯកសណ្ឋានបន្លំជាទាហាន (ប៉ារ៉ា) ប្រដាប់ដោយកាំភ្លើងវែងម៉ាក អាកា៤៧ ស្វ័យបត់មួយដើមបានដេញតាមគម្រាមដកហូតយកម៉ាស៊ីនថតរបស់លោក វណ្ណ សូផាត ក្នុងពេលដែលរូបគាត់បានចុះទៅកន្លែងកើតហេតុ ក្នុងនាមជាមន្ត្រីសម្របសម្រួលគម្រោងកំណែទម្រង់ដីធ្លីរបស់ ម.ស.ម.ក ដើម្បីឃ្លាំមើលសកម្មភាពនៅភូមិព្រែកជីក ដែលមានអ្នកភូមិមួយចំនួនកំពុងស្នើសុំឲ្យក្រុមហ៊ុននោះ បញ្ឈប់ការឈូសឆាយទៅលើចំការស្វាយចន្ទីដែលអ្នកភូមិម្នាក់បានអះអាងថាជាដីចំការរបស់គាត់។ ក្រុមការងាររបស់ ម.ស.ម.ក ត្រូវបានផ្តល់ព័ត៌មានដោយអ្នកភូមិមួយចំនួនថា ពួកគេកំពុងព្យាយាមដោះស្រាយបញ្ហាជាច្រើនពាក់ព័ន្ធនឹងការកាន់កាប់ដីដែលកំពុងមានជម្លោះ ប៉ុន្តែក្រុមហ៊ុនខាងលើនៅតែបន្តឈូសឆាយលើដីនោះ។ នៅនឹង

អាសយដ្ឋាន ផ្ទះលេខ ៣៩៨ ផ្លូវលេខ ៩៩, សង្កាត់បឹងត្របែក ខណ្ឌចំការមន, ប្រអប់សំបុត្រលេខ ២៥១៥, រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: ០២៣ ៧២៦ ៩០១ ទូរសារ: ០២៣ ៧២៦ ៩០២ អ៊ីមែល: info@cchrcambodia.org វេបសាយ: www.cchrcambodia.org

កន្លែងកើតហេតុ មន្ត្រីនគរបាលរូបនោះ បានធ្វើតាមការបង្គាប់បញ្ជារបស់ថៅកែក្រុមហ៊ុន គឺលោក ហេង ហ៊ុយ ដែលបញ្ជាគាត់ឲ្យដកម៉ាស៊ីនថតរបស់លោក វណ្ណ សូផាត ក្នុងគោលបំណងបំផ្លាញកស្តុតាងចោលពីការឈូសឆាយដំណាំស្វាយចន្ទីលើដីកំពុងមានទំនាស់នោះ។ ក្នុងកំឡុងពេលនោះផងដែរ លោក ហេង ហ៊ុយ ក៏បានគម្រាមលោក វណ្ណ សូផាត ថា "ប្រសិនបើអ្នកឯងចេញផ្សាយព័ត៌មានណាមួយអំពីព្រឹត្តិការណ៍កើតឡើងព្រឹកនេះ អ្នកឯងនឹងមានបញ្ហាជាមួយខ្ញុំ។"

ទាំងនេះគឺជាអំពើមិនត្រឹមត្រូវ និងខុសច្បាប់ ដែលមន្ត្រីនគរបាលស្តាប់បញ្ជាផ្ទាល់ពីជនសុីវិលម្នាក់នៅក្នុងព្រឹត្តិការណ៍នោះ។ ទោះជាមន្ត្រីនគរបាលនោះ ឬលោក ហេង ហ៊ុយ ពុំមានអំណាចក្នុងការដកហូតទ្រព្យសម្បត្តិរបស់លោក វណ្ណ សូផាត ឡើយ។ ការប្រព្រឹត្តរបស់មន្ត្រីនគរបាលនោះ និងលោក ហេង ហ៊ុយ គឺជាអំពើខុសច្បាប់ដែលមានចែងនៅក្នុងគោលការណ៍ច្បាប់ដូចខាងក្រោម:

ទី ១. មាត្រា ៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា "មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញបេសកម្មរបស់ខ្លួន ទទួលបញ្ជា ឬសុំបញ្ជាតែពីអាជ្ញាធរតុលាការ។" ក្នុងករណីនេះ មន្ត្រីនគរបាលនោះបានស្តាប់បញ្ជាពីជនសុីវិលម្នាក់ក្នុងការតាមដកហូតយកទ្រព្យសម្បត្តិ តែមិនមែនជាបញ្ជាពីអាជ្ញាធរតុលាការឡើយ។

ទី ២. ការដេញតាមគម្រាមយកម៉ាស៊ីនថត របស់លោក វណ្ណ សូផាត ដោយមន្ត្រីនគរបាលរូបនោះ គឺជាអំពើកំហែងយកទ្រព្យសម្បត្តិដែលមានចែងនៅក្នុងមាត្រា ៣៦៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

ទី ៣. ការបញ្ជាដោយលោក ហេង ហ៊ុយ ឲ្យមន្ត្រីនគរបាលរូបនោះដេញតាមគម្រាមដកយកម៉ាស៊ីនថតរបស់លោក វណ្ណ សូផាត គឺអំពើផ្តើមគំនិតឲ្យប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងមាត្រា ២៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

ទី ៤. បន្ថែមលើការរំលោភច្បាប់ព្រហ្មទណ្ឌ អំពើរបស់ជនទាំងពីររូប គឺមន្ត្រីនគរបាលរូបនោះ និងលោក ហេង ហ៊ុយ គឺជាការរំលោភទៅលើ មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលការពារសិទ្ធិរបស់ពលរដ្ឋខ្មែរគ្រប់រូបចំពោះ "សេរីភាពខាងការបញ្ចេញមតិ សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពខាងការប្រជុំ។"

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជួយអន្តរាគមន៍ស៊ើបអង្កេតដោយពេញលេញចំពោះអំពើនោះ និងធ្វើការណែនាំចំពោះមន្ត្រីនគរបាល គឺលោក ធី សុខុន ព្រមទាំងចាត់វិធានការណ៍

ច្បាប់ដ៏សមស្រប រួមទាំងដាក់ការចោទប្រកាន់តាមផ្លូវច្បាប់ទៅលើមន្ត្រីនគរបាលរូបនោះ ក្នុងស្មារតីមិនលំអៀង និងអនុលោមទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំ និងមានសុទិដ្ឋិនិយម ទៅលើវិធានការតាមផ្លូវច្បាប់ដ៏មានតម្លាភាព និងយុត្តិធម៌របស់ឯកឧត្តមក្នុងការពង្រឹងនីតិរដ្ឋ និងការគោរពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១២

អ៊ូ ទីរៈ